**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តឧត្តរមានជ័យ**

លេខៈ៤៩៧/២០ សជណ/ឧជ

ថ្ងៃសុក្រ ១៥កើត ខែអស្សុជ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤

ឧត្តរមានជ័យ ថ្ងៃទី០២ ខែ១០ ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ ២០២១

រដ្ឋបាលខេត្តឧត្តរមានជ័យនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ/សង្កាត់ និង ក្រុង/ស្រុកឆ្នាំ២០២១។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិ ឃុំ/សង្កាត់ និងគម្រោងក្រុង/ស្រុកទាំងអស់នៅទូទាំងរាជធានីខេត្តនៃ ព្រះរាជាណាចក្រកម្ពុជា ។ អ្នកទទួលការត្រូវបានបែងចែកជា ៣ ប្រភេទៈ

- ប្រភេទទី១ៈអ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារនិងការងារសំណង់បេតុង...។ល។ )
- ប្រភេទទី២ៈ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម....។ល។)
- ប្រភេទទី៣ៈ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេសឧបករណ៍ អណ្តូងស្នប់....។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈគ្រប់គ្រាន់ ដូចមាននៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗដែលបានស្នើសុំ យ៉ាងតិច០២គម្រោងក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជីព្រម ទាំងពិនិត្យមើលគុណភាពការងារភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយ និងម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូន ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តដើម្បីពិនិត្យ និងសម្រេច។ អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា បានជាប់ពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ត្រូវបានដកសិទ្ធិជាផ្លូវការជាអ្នកទទួលការហើយក៏មិន ត្រូវបាន ពិចារណាបញ្ចូលឈ្មោះទៅក្នុងបញ្ជីអ្នកទទួលការសម្រាប់ឆ្នាំ ២០២១ឡើយ ។

អាស្រ័យហេតុនេះបើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១សូមប្រញាប់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលខេត្តឧត្តរមានជ័យចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ៥:០០នាទីល្ងាច។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីនាឆ្នាំកន្លងមកក៏ត្រូវ ដាក់ពាក្យសុំចុះឈ្មោះក្នុបញ្ជីអ្នកទទួលការជាថ្មីឡើងវិញដែរ ។

អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគដោយឥតបង់ថ្លៃទំនាក់ ទំនងលេខទូរស័ព្ទ ០១២ ៤៩៦៧២។

អាស្រ័យហេតុនេះ សូមសាធារណជន និងលោកអ្នកទទួលការទាំងអស់ជ្រាបជាព័ត៌មាន។

**អភិបាលខេត្ត**

**ប៉ែន កុសល្យ**

ឯកសារ កាលប្បវត្តិ

Scanned with CamScanner